**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៣៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ សរសេរជាអក្សរកាត់ថា "**ក.ន.យ**" ជាអង្គភាពនៅអមក្រសួងយុត្តិធម៌ ដើម្បីជាសេនាធិការក្នុងការពិនិត្យ សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើវិស័យច្បាប់ និងវិស័យយុត្តិធម៌ដល់ក្រសួងយុត្តិធម៌ ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាព សង្គតិភាព និងអនុលោមភាពគតិយុត្ត ក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ក៏ដូចជាដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តការងារ និងអភិបាលកិច្ចល្អ ក្នុងវិស័យយុត្តិធម៌។

## ជំពូកទី២
## តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

**មាត្រា២ .-**

**ក.ន.យ**. មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ផ្តល់យោបល់ផ្នែកច្បាប់ ក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា ដែលជាសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ដើម្បីធានាបានសង្គតិភាព និងអនុលោមភាពគតិយុត្តជាមួយនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ទាក់ទងនឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងវិស័យយុត្តិធម៌
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ទាក់ទងនឹងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ព្រមទាំងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យយុត្តិធម៌ ជាមួយនិងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់សម្រាប់បម្រើឱ្យវិស័យយុត្តិធម៌
- ចូលរួមសហការតាមការចាំបាច់ជាមួយនិងអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ សំដៅបង្កើនប្រសិទ្ធភាពនៃការគោរពច្បាប់ និងអនុវត្តច្បាប់
- ចូលរួមសហការតាមការចាំបាច់ ជាមួយនិងអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ដើម្បីផ្សព្វផ្សាយច្បាប់ តាមរយៈការរៀបចំចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ក៏ដូចជាការរៀបចំ និងបោះពុម្ពផ្សាយព្រឹត្តបត្រច្បាប់ ជាដើម
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ ក៏ដូចជាកិច្ចដំណើរការនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៅក្នុងវិស័យយុត្តិធម៌
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ អំពីភាពចាំបាច់នានាសម្រាប់ការរៀបចំ និងការអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យយុត្តិធម៌
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ជំពូកទី៣
## សមាសភាពរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

**មាត្រា៣ .-**

**ក.ន.យ**. ដឹកនាំដោយប្រធានមួយរូប ដោយមានអនុប្រធាន និងសមាជិកមួយចំនួន សម្រាប់ជួយបំពេញការងារ ដែលត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ប្រធាន អនុប្រធាន និងសមាជិករបស់ **ក.ន.យ**. ត្រូវជ្រើសរើសចេញពីចំណោមបញ្ញវន្តដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ខាងផ្នែកនីតិសាស្ត្រ រដ្ឋបាលសាធារណៈ វិទ្យាសាស្ត្រនយោបាយ ឬ វិទ្យាសាស្ត្រសង្គម និងមានបទពិសោធន៍ការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងវិស័យច្បាប់ ឬវិស័យយុត្តិធម៌។

## ជំពូកទី៤
## កិច្ចដំណើរការរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

**មាត្រា៤ .-**

អនុប្រធាន និងសមាជិក **ក.ន.យ**. ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ១ (មួយ) រូប ឱ្យកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំតាមការចាំបាច់។

**ក.ន.យ**. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ក្នុងការបំពេញការងាររបស់ខ្លួន។

**មាត្រា៥ .-**

**ក.ន.យ**. មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងចៅក្រម និងព្រះរាជអាជ្ញា ឬស្នើសុំអ្នកជំនាញផ្នែកច្បាប់ផ្សេងៗ ពីស្ថាប័នឯកជន ឬស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន។

**មាត្រា៦ .-**

**ក.ន.យ**. អាចមានទីប្រឹក្សា និងជំនួយការមួយចំនួនតាមការចាំបាច់។

ទីប្រឹក្សា និងជំនួយការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

**មាត្រា៧ .-**

**ក.ន.យ**. មានលេខាធិការដ្ឋានមួយ ថ្នាក់ស្មើនាយកដ្ឋានចំណុះក្រសួងយុត្តិធម៌ ជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួន។

លេខាធិការដ្ឋាន **ក.ន.យ**. ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **ក.ន.យ**. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ជំពូកទី៥
## ប្រភពធនធានរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

**មាត្រា៨ .-**

**ក.ន.យ**. មានប្រភពធនធាន ផ្គត់ផ្គង់ដោយថវិកាជាតិ នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងយុត្តិធម៌។

**គ.ន.ឃ.** មានសិទ្ធិទទួលធនធាន និងថវិកាពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន ស្របតាមច្បាប់និងនីតិវិធីជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ